ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

---

សំណុំរឿងរដ្ឋប្បវេណី **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ៤៣៨ **តុលាការកំពូល**

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤

សាលដីកា បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦

លេខ : ៧៣ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ខិត មុន្នី** | ជាប្រធាន |
| ២- | លោក | សោម សិរីវឌ្ឍ | ជាចៅក្រមរបាយការណ៍ |
| ៣- | លោក | ប៉ែន សារឿន | ជាចៅក្រម |
| ៤- | លោក | ម៉ុង មុន្នីចរិយា | ជាចៅក្រម |
| ៥- | លោក | យូរ ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ២៦ " ជ " ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៦៥ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

-ដើមចោទឈ្មោះប៊ួន ឃីម ( ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៦ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ី តម្បាញ ទីលំនៅសព្វថ្ងៃភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឡាយ ស្រេង "ស" ម្តាយឈ្មោះប៊ួន ម៉ាប់ "រ" ប្តីឈ្មោះជូរ ទ្រី មានកូន៧នាក់ ។

-មានមេធាវីអ្នកស្រី ពីង ធីតា

-ចុងចម្លើយឈ្មោះជា បូរិន ( ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ របររកស៊ី តម្បាញ ទីលំនៅសព្វថ្ងៃភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ឪពុកឈ្មោះជា មាច "ស" ម្តាយឈ្មោះឡាយ សុខឡេង "រ" ។

-មានមេធាវីលោក ម៉ន កែវស៊ីវិទ្ធ

**កម្មវត្ថុ** : ប្តឹងសុំបដិសេធសំបុត្រអាពាហ៍ពិពាហ៍ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២៣៨ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះជា ប៊ូរិន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៦ "ជ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៣៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០០៣របស់អ្នកស្រីប៊ូន ឃីម ប្ដឹងសុំបដិសេធសំបុត្រអាពាហ៍ពិពាហ៍ពីឈ្មោះលោកជា ប៊ូរិន ដោយសំអាងហេតុថា កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៣ខ្លួនបាត់កូនស្រីឈ្មោះជូ ស្រីឡែន ក្រោយមកទើបដឹងថា ឈ្មោះជា ប៊ូរិន នៅក្បែរផ្ទះខ្លួនបបួលកូនស្រីខ្លួនរត់ទៅភ្នំពេញផ្ទះរបស់ឈ្មោះមុំ ក្រោយមកឈ្មោះជា ប៊ូរិន ក៏បបួលកូនស្រីខ្លួនទៅខេត្តស្វាយរៀងជាផ្ទះរបស់បងប្អូន ជា ប៊ូរិន រស់នៅទីនោះអស់រយៈពេល១ខែ ២១ថ្ងៃហើយឈ្មោះនេះបានចាប់ធ្វើបាបរំលោភកូនស្រីរបស់ខ្លួននឹងគំរាមកំហែងអោយកូនរបស់ខ្លួនដោះខ្សែករចំនួន២ជីលក់ចាយ ឈ្មោះជា ប៊ូរិន បានយកក្រដាសមកឱ្យកូន របស់ខ្លួនផ្ដិតមេដៃដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ទើបឈ្មោះជា ប៊ូរិន យកកូនស្រីខ្លួនមកស្រុកមុខកំពូលដោយមានកាន់សំបុត្រអាពាហ៍ពិពាហ៍ពីខេត្តស្វាយរៀងទៀតផង ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២០"វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងរបស់ឈ្មោះប៊ូន ឃីម ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធសំបុត្រអាពាហ៍ពិពាហ៍លេខ០១ សៀវភៅអាពាហ៍ពិពាហ៍លេខ០១/០៣ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៣ របស់ឃុំបាទី ស្រុកចន្ទ្រា ខេត្តស្វាយរៀង ចោលជាអាសារបង់ ។ ដោយចាត់ទុកជាមោឃៈនូវចំណងអាពាហ៍ពិពាហ៍មិនស្របច្បាប់រវាងឈ្មោះជា ប៊ូរិន និងនារីឈ្មោះជូរ ស្រីឡែន។ តាមមាត្រា៥ , ១១ ,១២ , ១៣ ,១៤ , ២២ , ២៣ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៣-បង្គាប់ឱ្យជា ប៊ូរិន ជាចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដីចំនួន៧.០០០រៀលគឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ឹងចំនួន១.៨០០រៀល ។ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០រៀល និង រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល ។ តែប្រាក់នេះត្រូវកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចហើយនៅតុលាការខេត្តកណ្ដាល ។ នៅពេលសាលក្រមស្ថាពរបង្គាប់ឱ្យឈ្មោះជា ប៊ូរិន សងប្រាក់ទៅអោយដើមចោទវិញ ។

៤-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទនិងចុងចម្លើយ បើកផ្លូវប្ដឹងឧទ្ធរណ៍រយៈពេលពីរខែ គិតពីថ្ងៃនេះទៅ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៦៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះជា ប៊ូរិន ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២០"វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្ដាល លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ២៦"ជ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះជា ប៊ូរិន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២០ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្ដាលទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្ស៊ីងនឹងពន្ធចុះបញ្ជីក្ដី២៥០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀល សរុបចំនួន១៣០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដីឈ្មោះជា ប៊ូរិន ជូរ ស្រីឡែន និង មេធាវីលោកម៉ន កែវស៊ីរិន ការពារចុងចម្លើយ ។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ២៣៨ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះជា ប៊ូរិន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៦"ជ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះជា ប៊ូរិន ។

-បានឃើញសារណាតប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះប៊ួន ឃីម ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : ជាគោលការណ៍អាពាហ៍ពិពាហ៍ធ្វើឡើងដោយស្ម័គ្រចិត្តគ្មានអ្នកណាមកបង្ខិតបង្ខំឡើយ ហើយការបង្ខិតបង្ខំត្រូវទុកជាមោឃៈ អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះជា ប៊ូរិន ( ជាម្ចាស់បណ្ដឹងសាទុក្ខ) នៅពេលសវនាការថា : ខ្លួនប្ដឹងមិនសុខចិត្តនឹងការសំរេចសេចក្ដីរបស់សាលាឧទ្ធរណ៍ដែលកាត់សេចក្ដីមិនត្រឹមត្រូវ ។សំបុត្រអាពាហ៍ពិពាហ៍នេះ ខ្លួន និង ឈ្មោះជូរ ស្រីឡែន បានព្រមព្រៀងគ្នាចុះ គ្មានអ្នកណាមកបង្ខិតបង្ខំឡើយ ។

ខ្លួនមិនសុខចិត្តលប់សំបុត្រអាពាហ៍ពិពាហ៍នេះទេខ្លួននៅតែយកប្រពន្ធរបស់ខ្លួនឈ្មោះជូរ ស្រីឡែនដដែល ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះប៊ួន ឃីម ( ជាចុងបណ្ដឹងសាទុក្ខ) នៅពេលសវនាការថា : ខ្លួនសូមឱ្យតុលាការលប់ សំបុត្រអាពាហ៍ពិពាហ៍នេះចោល ព្រោះសំបុត្រអាពាហ៍ពិពាហ៍ ខ្លួនជាម្ដាយមិនបានដឹង ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះ ជូរ ស្រីឡែន នៅពេលសវនាការថា : នៅពេលដែលចុះសំបុត្រអាពាហ៍ពិពាហ៍ គឺដោយគេបង្ខិតបង្ខំខ្លួន ។ ខ្លួនសូមលប់សំបុត្រអាពាហ៍ពិពាហ៍ចោល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកម៉ន កែវស៊ីរិន ជាមេធាវីការពារឱ្យចុងចម្លើយនៅពេលសវនាការថា : ការចុះសំបុត្រអាពាហ៍ពិពាហ៍ធ្វើឡើងដោយមិនមានការបង្ខិតបង្ខំទេ ហើយបានរស់នៅជាមួយគ្នាបានបួនខែ ។ ពេលដែលកូនក្តីខ្លួន និង ជូរ ស្រីឡែន មកដល់ផ្ទះ ស្រាប់តែម្តាយរបស់នាង គាត់មកបំបែកប្តីប្រពន្ធកូនក្តីរបស់ខ្លួន ។ ខ្លួនសំណូមពរសុំអោយតុលាការទទួលស្គាល់សំបុត្រអាពាហ៍ពិពាហ៍សៀវភៅបញ្ជាក់លេខ០១/២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។ សុំឱ្យឯកឧត្តមប្រធានបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីធ្វើការជំនុំជំរះសារជាថ្មីឡើងវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រីពីង ធីតា ជាមេធាវីឱ្យការពារដើមចោទ នៅពេលជំនុំជំរះថា : សំបុត្រអាពាហ៍ពិពាហ៍នេះធ្វើឡើងដោយផ្ទុយនឹងច្បាប់ កូនក្តីខ្លួនមិនទាន់គ្រប់អាយុ១៨ឆ្នាំផង ក្នុងការរៀបអាពាហ៍ពិពាហ៍ដែលច្បាប់បានកំណត់ ។ ដូច្នេះការចុះអាពាហ៍ពិពាហ៍នេះ ធ្វើឡើងផ្ទុយនឹងច្បាប់ផ្ទុយនឹងមាត្រាទី៥ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ សំបុត្រអាពាហ៍ពិពាហ៍នេះមិនត្រឹមត្រូវតាមច្បាប់ទេ សូម្បីតែឈ្មោះឪពុកសងខាងក៏ក្លែងដែរ ។ ហើយសំបុត្រអាពាហ៍ពិពាហ៍នេះធ្វើឡើងផ្ទុយនឹងមាត្រា២២ , ២៣ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ សូមក្រុមប្រឹក្សាជំនុំជំរះតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣៨ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់លោកជា បូរិន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា នៅពេលសវនាការនេះ នាងជូរ ស្រីឡែន បានទាមទារសុំមោឃះភាពសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៣ ដោយហេតុថា មានការបង្ខិតបង្ខំក្នុងការធ្វើលិខិតនេះ ។ ចំណែកឯលោក ជា បូរិន ពុំសុខចិត្តលុបសំបុត្រនេះទេ ដែលតាមមាត្រា៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ បានចែងថា ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៦ " ជ " ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខតុក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ២៣៨ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់លោក ជា ប៊ូរិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ២៦"ជ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី ប៊ួន ឃឹម បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។ ហើយតំរូវឱ្យលោកជា ប៊ូរិន សងប្រាក់ចំនួន១៩.០០០រៀលនេះ ទៅអ្នកស្រីប៊ួន ឃឹម វិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ។